**សេចក្តីថ្លែងការណ៍របស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស លោកស្រី ណាវី ភីឡៃ នៅក្នុងឱកាសទិវាអន្តរជាតិគាំទ្រជនរងគ្រោះដោយអំពើទារុណកម្ម ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤**

ជារៀងរាល់ថ្ងៃ នៅក្នុងពន្ធនាគារ មន្ទីរនគរបាល និងនៅកន្លែងឃុំឃាំងផ្សេងៗ ទាំងផ្លូវការ និងទាំងសម្ងាត់ ស្ត្រី បុរស និងកុមារ ត្រូវបានគេធ្វើទារុណកម្មដោយចេតនា និងយ៉ាងសាហាវយង់ឃ្នង។ ពួកគេត្រូវទទួលរងការធ្វើទុក្ខទោស ការឈឺចាប់ និងមើលងាយមើលថោក និងអាចត្រូវបានគេរៀបចំឲ្យមើលឃើញសមាជិកគ្រួសារដែលងាយរងគ្រោះរបស់ខ្លួន កំពុងត្រូវគេធ្វើទារុណកម្ម។ ពួកគេត្រូវបានដាក់ឲ្យនៅឯកោតែម្នាក់ឯងរយៈពេលដ៏យូរ និងសួរចម្លើយរយៈពេលដ៏វែង ព្យាបាលផ្នែកវេជ្ជសាស្ត្រ ម្ហូបអាហារ ត្រូវបានកាត់បន្ថយសម្រាប់រយៈពេលយូរ។

ជនរងគ្រោះរាប់សែននាក់ និងរាប់ម៉ឺនកន្លែងបែបនេះ មាននៅបណ្តាប្រទេស គ្រប់ទ្វីបទាំងអស់ នៅទូទាំងពិភពលោក។ ក្នុងចំណោមប្រទេសទាំងនោះ រួមមាន ប្រទេសកាន់អំណាចផ្តាច់ការ ប្រទេសដែលស្ថិតក្នុងសម័យអន្តរកាល និងរដ្ឋជាច្រើនដែលមានប្រពៃណីយូរអង្វែង ដែលកាន់របបប្រជាធិបតេយ្យអាស្រ័យសភា។

ការធ្វើទារុណកម្មគឺជាបទល្មើសមួយពិតប្រាកដ។ ក្រោមអនុសញ្ញា អ.ស.ប ប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ហាមប្រាមគ្រប់កាលៈទេសៈទាំងអស់ ដោយគ្មានករណីលើកលែងឡើយ ទោះជាដើម្បីបុព្វហេតុសន្តិសុខជាតិ ការប្រយុទ្ធប្រឆាំងនឹងភេរ វកម្ម ការគំរាមកំហែងដោយសង្គ្រាម ឬភាពអាសន្នជាសាធារណៈផ្សេងទៀតក្តី មិនអាចយកមកសំអាងដោះសារសម្រាប់ការធ្វើទារុណកម្មបានឡើយ។ រដ្ឋទាំងឡាយមានកាតព្វកិច្ចស៊ើបអង្កេត និងផ្តន្ទាទោសការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ហើយត្រូវរិះរកគ្រប់មធ្យោបាយទាំងអស់ ដើម្បីបង្ការទប់ស្កាត់សកម្មភាពទាំងនេះ មិនឲ្យកើតមានឡើង។

ជាការពិតណាស់ ការហាមប្រាមការធ្វើទារុណកម្ម មានវិសាលភាពលាតសន្ធឹងហួសពីព្រំដែនជាតិទៅទៀត៖ រដ្ឋទាំងឡាយ អាចមិនបញ្ជូនបុគ្គលណាមួយត្រឡប់មកប្រទេសមួយដែលបុគ្គលនោះត្រូវប្រឈមនឹងហានិភ័យនៃការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌បានឡើយ។ ផ្ទុយទៅវិញ រដ្ឋទាំងឡាយមានកាតព្វកិច្ចស៊ើបអង្កេត និងផ្តន្ទាទោសជនទាំងឡាយដែលទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម ដែលបានរកឃើញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន - ទោះបីជាការធ្វើទារុណកម្មនោះ បានកើតមានតាំងតែពីប៉ុន្មានឆ្នាំមុន ហើយនៅក្នុងប្រទេសមួយផ្សេងទៀតក៏ដោយ។

ម្យ៉ាងវិញទៀត ព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម មិនអាចប្រើប្រាស់នៅក្នុងតុលាការឡើយ។ នេះរួមទាំងសវនាការបិទទ្វារ ដូចជា តុលាការយោធា និងសវនាការដែលរដ្ឋាភិបាលបានធ្វើជាឯកជន ដោយខ្លាចមានការលេចធ្លាយព័ត៌មានរសើប។ វាមានន័យផងដែរថា ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់ មិនអាចប្រើប្រាស់ដោយស្របច្បាប់នូវព័ត៌មានដែលបានមកពីការធ្វើទារុណកម្មបានឡើយ។ ការប្រើប្រាស់បែបនេះ មិនត្រឹមតែនាំឲ្យខូចដល់ការហាមប្រាមដាច់ខាតនៃការធ្វើទារុណកម្ម ដោយការបង្កើតទីផ្សារព័ត៌មាន ដែលការទទួលបានព័ត៌មានតាមមធ្យោបាយបែបនេះ វានឹងនាំឲ្យមានការឃុបឃិតគ្នាប្រព្រឹត្តអំពើព្រៃផ្សៃ។

ជារៀងរាល់ថ្ងៃ ការិយាល័យខ្ញុំ និងសកម្មជនសិទ្ធិមនុស្សជាច្រើន ទទួលរបាយការណ៍ថ្មីៗអំពីការធ្វើទារុណកម្មនៅទ្វីបអាស៊ី អាហ្វ្រិក អាមេរិក អឺរ៉ុប និងអូសេអានី។ ការធ្វើទារុណទាំងនោះ មានចាប់ពីការវាយដំធ្ងន់ធ្ងររហូតដល់ការប្រមាថផ្លូវភេទជាសាធារណៈ និងការរំលោភសេពសន្ថវៈ ការប្រើគ្រឿងម៉ាស៊ីនដាក់លាក់មួយចំនួនដើម្បីធ្វើឱ្យឈឺចាប់ ការសម្លាប់ធ្វើត្រាប់ និងកាតព្វកិច្ចក្នុងការបង្ហាញសក្ខីកម្មពីការឈឺចាប់ត្រូវធ្លាក់លើកុមារ ឬសមាជិកផ្សេងទៀតក្នុងគ្រួសារ។ ស្ទើរតែគ្រប់ករណីទាំងអស់ អ្នកដែលបានបញ្ជា និងបានប្រព្រឹត្តអំពើរំលោភបំពានទាំងនេះ គេចផុតពីសំណាញ់យុត្តិធម៌។ ករណីទាំងនេះ ត្រូវបានបង្កើតឡើងក្រោមរនាំងបិទបាំងពីវិធានការការពារជាតិ ឬវិធានការជាក់ស្តែងសម្រាប់ការលើកលែងទោស ហើយអ្នកការពារពួកគេ ធ្វើជាមិនដឹងមិនឮអំពីហេតុការណ៍ដែលបានប្រព្រឹត្តក្រោមអំណាចរបស់ខ្លួន។

រដ្ឋាភិបាលទាំងឡាយដែលរួមគំនិតក្នុងបញ្ហានិទណ្ឌភាព  មិនត្រឹមតែរំលោភសិទ្ធិជនរងគ្រោះ ក្នុងការទទួលបានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងរំលោភសិទ្ធិរបស់យើងទាំងអស់គ្នាផងដែរ។ ដោយទទួលស្គាល់ចំពោះបញ្ហានេះ មានរដ្ឋចំនួន១៥៤ បានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងទារុណកម្ម - ក៏ប៉ុន្តែរដ្ឋជាច្រើនក្នុងចំណោមនោះ បន្តអត់ឱនចំពោះទង្វើបែបនេះ។ រដ្ឋចំនួន៤១ ទៀត បានបដិសេធការផ្តល់សច្ចាប័នលើអនុសញ្ញានេះ ហើយរដ្ឋមួយចំនួនក្នុងចំណោមនោះ បន្តអនុញ្ញាតឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌លើជនជាប់ឃុំ ទោះជាដោយវារហិត ឬដោយច្បាប់ក្តី។ រដ្ឋត្រូវធានាផងដែរថា ជនរងគ្រោះដោយការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌ ទទួលបានការដោះស្រាយពេញលេញ និងមានប្រសិទ្ធភាព និងផ្តល់សំណង។ ហើយកាតព្វកិច្ចនេះផងដែរ ត្រូវបានធ្វេសប្រហែសជាប្រព័ន្ធ។ ជនរងគ្រោះត្រូវបានគេទុកចោល មិនយកចិត្តទុកដាក់គិតគូ ហើយបន្ទុកនៃការស្តារនីតិសម្បទារបស់ពួកគេ បានក្លាយជាបន្ទុករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលអង្គការភាគច្រើន ត្រូវបានគាំទ្រដោយមូលនិធិ អ.ស .ប គាំទ្រដល់ជនរងគ្រោះដោយការធ្វើទារុណកម្ម។

បច្ចុប្បន្ននេះ មានប្រទេសកាន់តែច្រើនឡើងៗ ដែលការធ្វើទារុណកម្មកើតមាននៅក្នុងមណ្ឌលឃុំឃាំង ដែលបានបង្កើតឡើងដោយកងជីវពលក្រៅផ្លូវការ និងតួអង្គមិនមែនរដ្ឋផ្សេងទៀត។ កាលពីពេលថ្មីៗនេះ ការិយាល័យខ្ញុំបានចងក្រងឯកសារទាក់ទងនឹងករណីនៃការធ្វើទារុណកម្មដោយក្រុមបក្សប្រឆាំង នៅអ៊ុយក្រែន និង ស៊ីរី - រួមទាំង ដោយកងកម្លាំងនៃរដ្ឋអ៊ីស្លាមនៃប្រទេសអ៊ីរ៉ាក់ និង Levant (ISIL) ដែលកាលពីពេលថ្មីៗនេះ បានចូលលុកលុយយ៉ាងខ្លាំងនៅក្នុងប្រទេសអ៊ីរ៉ាក់។

ជាការពិតណាស់ដែលថា ក្រុមនេះយល់ថា ពួកគេមានភាពស៊ាំទៅនឹងវិធានច្បាប់អន្តរជាតិ។ ការគិតរបស់ពួកគេនោះគឺខុសហើយ។ មន្រ្តីរដ្ឋាភិបាល តំណាងរាស្រ្ត ចៅក្រម មេធាវី អ្នកជំនាញផ្នែកវេជ្ជសាស្រ្ត មន្រ្តីយោធា កងកំលាំងសន្តិសុខ មន្រ្តីអនុវត្តច្បាប់ មន្រ្តីពន្ធនាគារ ហើយមិនត្រឹមតែប៉ុណ្ណឹងទេ រួមទាំងមេដឹកនាំក្រុមប្រឆាំង កងជីវពល និងពួកឧក្រិដ្ឋជន ត្រូវតែដឹងឲ្យបានច្បាស់ថា ពួកគេត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងទទួលខុសត្រូវផងដែរ ចំពោះសកម្មភាពដែលមិនមែនជាទង្វើរបស់ខ្លួន មានអាទិ៍ ការខកខានក្នុងការបង្ការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ និងការការពារជនរងគ្រោះ។

ជារៀងរាល់ឆ្នាំ ភាគច្រើនបំផុតនៅអាមេរិកឡាទីន មនុស្សជាច្រើនដែលបានប្រព្រឹត្តអំពើទារុណកម្ម កាលពីម្ភៃឆ្នាំ ឬលើសពីនេះ ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោស។ ប្រព័ន្ធផ្លាស់ប្តូរ របបផ្លាស់ប្តូរ - ប៉ុន្តែច្បាប់ហាមប្រាមការធ្វើទារុណកម្ម ស្ថិតនៅដដែល គ្មានការផ្លាស់ប្តូរឡើយ។

នៅថ្ងៃទី២៦ ខែមិថុនា យើងទាំងអស់គ្នា នៅក្នុងសហគមន៍សិទ្ធិមនុស្ស រៀបចំទិវាគោរពដល់មនុស្សជាច្រើនដែលរងគ្រោះ ដោយការធ្វើទារុណកម្មនៅលើពិភពលោក។ យើងបញ្ជាក់អះអាងជាថ្មីនូវការសន្យារបស់យើងថានៅថ្ងៃណាមួយ ជនរងគ្រោះគ្រប់រូបនឹងទទួលបានសិទ្ធិរបស់ខ្លួន ឲ្យគេទទួលស្គាល់យុត្តិធម៌ និងការស្តារនីតិសម្បទា។ យើងនិយាយច្បាស់ៗ និងឮសំលេងខ្លាំងៗ ដូច្នេះហើយ មន្ត្រីទាំងឡាយនៅគ្រប់ទិសទីនឹងស្តាប់ឮសារនេះ៖ គ្មានអំពើទារុណកម្ម ឬគ្មានការប្រើប្រាស់ព័ត៌មានដែលមកបានពីការធ្វើទារុណកម្ម អាចត្រូវបានអត់ឱនឲ្យបានឡើយ។ បន្ទាប់មក យើងងាកមករកការងាររបស់យើងឈានទៅធានាថា ការធ្វើទារុណកម្ម ទោះជាកើតមាននៅទីណាកន្លែងណាក៏ដោយ ត្រូវតែចងក្រងជាឯកសារ ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស ហើយត្រូវតែជួសជុលសំណងការខូចខាតដល់ជនរងគ្រោះជាដាច់ខាត - ដើម្បីឲ្យពួកគេអាចងើបចេញផុតពីរបួសផ្លូវកាយដ៏សាហាវយង់ឃ្នង និងពីការភ័យខ្លាចដែលពួកគេបានទទួលរង។

**មូលនិធិស្ម័គ្រចិត្ត អ.ស.ប សម្រាប់ជនរងគ្រោះដោយអំពើទារុណកម្ម ដែលត្រូវបានគ្រប់គ្រងដោយការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស បានផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការទាំងឡាយដែលផ្តល់ជំនួយផ្លូវចិត្ត វេជ្ជសាស្ត្រ និងសង្គម ដល់ជនរងគ្រោះដោយអំពើទារុណកម្ម ក៏ដូចជា ជំនួយផ្នែកច្បាប់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ។ http://donatenow.ohchr.org/torture/.។**

**ចប់**

*ដើម្បីសិក្សាបន្ថែមអំពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សូមចូលទីកាន់គេហទំព័រ http://www.ohchr.org*

*សម្រាប់ការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទងមក រ៉ូប៊ើត ខូលវីល (Rupert Colville) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧ ៦៧ / អ៊ីម៉េល rcolville@ohchr.org ) ឬ រ៉ាវីណា សាំដាសានី (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៦៩ / អ៊ីម៉េល rshamdasani@ohchr.org )*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គ៊ល៖**Google+ gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR

**ផែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល ៖** http://uhri.ohchr.org/en